**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**

**លោកស្រី ហ៊ុយ ដាលីន អធិការ នៃអគ្គាធិការដ្ឋាន និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយចិត្តក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសក **កែវ សុវណ្ណសេរី** ដែលត្រូវជាស្វាមី លោកស្រី **ហ៊ុយ ដាលីន** អធិការ នៃអគ្គាធិការដ្ឋាន បានទទួលមរណភាពនៅថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ ក្នុងជន្មាយុ ៥៣ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការជាមួយលោកស្រី និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ ឧបាសក **កែវ សុវណ្ណសេរី** ដែលជាស្វាមី និលោកឪពុកជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ ឧបាសក **កែវ សុវណ្ណសេរី** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកស្រី និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ ចន្ទ ១៣រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

ហ៊ុន-សុខា